# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍វឌ្ឍភាពស្តីពី
# វិធីសាស្ត្រអនុវត្តរេដបូកនៅកម្ពុជា



**កម្មវិធីរេដបូកកម្ពុជា**

CAMBODIA REDD+ PROGRAMME

ខែធ្នូ
ឆ្នាំ២០២១

# របាយការណ៍វឌ្ឍភាពស្តីពី
# វិធីសាស្ត្រអនុវត្តរេដបូកនៅកម្ពុជា

ខែធ្នូ ឆ្នាំ២០២១

# មាតិកា


១. ធនធានដ៏មានតំលៃកំពង់ស្ថិតក្រោមសម្ពាធ.................................................០៦

២. វឌ្ឍភាពទទួលបានរហូតមកដល់ពេលនេះបានមកជាមួយនឹងការចំណាយ..........................១២

៣. រេដបូក៖ មធ្យោបាយការពារ និរន្តរភាពព្រៃឈើ និងកែលម្អគម្របព្រៃឈើ.........................១៨

៤. កម្ពុជាត្រៀមខ្លួនរួចជាស្រេចសម្រាប់រេដបូក..................................................២៤

៥. ការរៀបចំសសរស្តម្ភរេដបូក.............................................................៣០

៦. សុខដុមនីយកម្មបដិបត្តិរេដបូកឬការផ្តល់ឥណទានទៅកន្លែងដែលសមទទួលបាន..................៣៨

៧. ឆ្ពោះទៅកាន់ការអនុវត្ត៖ ជំហានបន្ទាប់.....................................................៤៤




# ១. ធនធានដ៏មានតំលៃ កំពុងស្ថិតក្រោមសម្ពាធ



កម្ពុជាជាប្រទេសមួយដែលសម្បូរធនធានធម្មជាតិ និងជីវៈចម្រុះច្រើនជាងគេបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ធនធានព្រៃឈើដ៏មហាសាលនេះបានផ្តល់ជាទីជម្រកសម្រាប់ពពួកសត្វ រុក្ខជាតិ និងជីវៈចម្រុះដ៏សម្បូរបែប ហើយមានទំនាក់ទំនងយ៉ាងសំខាន់ទៅនិងវប្បធម៌និងការរស់នៅរបស់ប្រជាជន។ ប្រាសាទបុរាណជាច្រើនបានបង្កប់ខ្លួននៅក្នុងព្រៃ ហើយវាក៏បានបង្ហាញពីការគោរពទៅលើដួងព្រលឹងនិងវិញ្ញាណផងដែរ។ ធនធានទាំងនេះ មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការជួយទ្រទ្រង់ដល់ជីវភាពរស់នៅរបស់ប្រជាជន និងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាដើម្បីឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព។

ក្រាហ្វិកទី១៖ ផែនទីការប្រើប្រាស់ដី / គម្របដីនៅកម្ពុជាឆ្នាំ២០១៨ (ប្រភព៖ លេខាធិការដ្ឋានរេដបូក)




| អក្សរតាង | ប្រភេទដី | ទំហំ (ហិចតា) |
|---|---|---|
| FL | ដីព្រៃឈើ | ២,៧៩៨,៦៥៩ |
| CL | ដីកសិកម្ម | ១,០៣៨,៧០៨ |
| GL | ដីវាលស្មៅ | ៣,២០៥,១៤០ |
| WL | ដីលំនៅដ្ឋាន | ១២២,៤១២ |
| S | ដីសើម | ៥៩៣,៥០១ |
| OL | ដីផ្សេងទៀត | ៣១,២៩៣ |

យ៉ាងណាមិញ ព្រៃឈើនៅកម្ពុជានៅតែទទួលរងនូវការគំរាមកំហែង។ នៅក្នុងឆ្នាំ២០១០ ព្រៃឈើកម្ពុជាគ្របដណ្តប់លើផ្ទៃដីចំនួន ៥៧% នៃផ្ទៃដីប្រទេសទាំងមូល។ នៅឆ្នាំ២០១៨ គម្របព្រៃឈើបានធ្លាក់មកនៅត្រឹមតែ៤៥%តែប៉ុណ្ណោះ។[1] ការបាត់បង់នេះកើតមានឡើងចំពេលដែល បញ្ហាបន្ទាន់នៃវិបត្តការប្រែប្រួលអាកាសធាតុបាននឹងកំពង់កើតមានឡើងនៅជុំវិញពិភពលោក ដូចជាភ្លើងឆេះព្រៃ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ហើយនិងគ្រោះធម្មជាតិដែលកើតមានឡើងនៅគ្រប់ទីកន្លែង។ កម្ពុជាគឺជាប្រទេសមួយដែលងាយនឹងរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ។ គ្រោះធម្មជាតិនេះបានបណ្តាលឲ្យបាត់បង់ជីវិតមនុស្ស សត្វនិងថែមទាំងប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងធនធានធម្មជាតិជាច្រើនផងដែរ។[2]

ក្នុងនាមជាប្រទេសដែលបានចុះហត្ថលេខាក្នុងឆ្នាំ២០១៥លើកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ស្តីពីការប្រែប្រួលអាកាសធាតុ កម្ពុជាបាននឹងកំពុងឆ្លើយតបទៅនឹងសេចក្តីអំពាវនាវជាសកលឱ្យមានមហិច្ឆិតាខ្ពស់ក្នុងដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ រួមទាំងការដាក់ចេញនូវផែនការយុទ្ធសាស្រ្តនានា ដើម្បីរួមចំណែកដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបណ្តាលឲ្យមានការកើនឡើងកំដៅផែនដីនិងសម្របសម្រួលខ្លួនទៅនឹងវិបត្តិនៃការប្រែប្រួលអាកាសធាតុ។ ភាគច្រើននៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ ផ្តោតសំខាន់ទៅលើការកាត់បន្ថយការបាត់បង់និងរេចរិលព្រៃឈើ គួបផ្សំនិងការអភិរក្ស និងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព ដែលរួមចំណែកសំខាន់ដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការស្រូបកាបូនពីបរិយាកាស។

នៅឆ្នាំ២០២០ កម្ពុជាបានដាក់ចេញនូវផែនការសកម្មភាពអាកាសធាតុជាតិរយៈពេល៥ឆ្នាំ ស្តីពីការរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC)។ ផែនការសកម្មភាពនេះមានទិសដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឲ្យបានប្រមាណ ៤២%នៅឆ្នាំ២០៣០ដែលពាក់កណ្តាលនៃចំនួននេះ នឹងសម្រេចបានតាមរយៈការផ្លាស់ប្តូរនៅក្នុងវិស័យព្រៃឈើ និងការប្រើប្រាស់ដី។ កម្ពុជាក៏មានគោលដៅសម្រេចការលុបបំបាត់អាត្រានៃការបាត់បង់ព្រៃឈើឱ្យបានទាំងស្រុងនៅឆ្នាំ២០៤០។[3]

កម្ពុជាបានបង្កើតមូលដ្ឋានគ្រឹះយ៉ាងរឹងមាំរួចមកហើយ ក្នុងការសម្រេចឲ្យបាននូវគោលដៅអស់ទាំងនេះ ដោយបានចំណាយពេលជិតមួយទសវត្សក្នុងការរៀបចំយន្តការអនុវត្តរេដបូក ការកាត់បន្ថយការបាត់បង់ និងការរេចរឹលព្រៃឈើតាមរយៈការអភិរក្សនិងគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព។ ជាយន្តការមួយ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការដោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស រេដបូកគឺជាផ្នែកមួយនៃឱកាសជាប្រវត្តិសាស្រ្តសកល ដើម្បីកៀរគរថវិកាគាំទ្រដល់ការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

កូនសៀវភៅស្តីពីរេដបូកនេះពិព៌ណនាពីដំណើររបស់កម្ពុជាក្នុងការរៀបចំការអនុវត្តរេដបូក ដល់អ្នកធ្វើគោលនយោបាយ អ្នកជំនាញព្រៃឈើ សង្គមស៊ីវិល អ្នកជំនាញការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងភាគីពាក់ព័ន្ធផ្សេងៗទៀតដែលមានចំណេះដឹងទូទៅផ្នែកអាកាសធាតុនិងព្រៃឈើ។ កូនសៀវភៅនេះក៏ពិព៌ណនាផងដែរពីដំណើរការ លទ្ធផលសម្រេចបាន គំនិតផ្តួចផ្តើមនានា ព្រមទាំងផែនការអនាគត។ ក្នុងការផ្តល់ការណែនាំជាមូលដ្ឋានពីរបៀបដែលរេដបូកអាចដំណើរការបាន សៀវភៅនេះក៏បង្ហាញផងដែរពីតម្លៃសក្តានុពលនៃយន្តការរេដបូក រួមទាំងការងារត្រួសត្រាយឈានមុខគេរបស់កម្ពុជា ក្នុងការរៀបចំប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូក ដើម្បីគ្រប់គ្រងដល់គណនេយ្យកាបូន។ បទពិសោធន៍នៃការបង្កើតប្រព័ន្ធនេះនឹងអាចផ្តល់អត្ថប្រយោជន៍ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍជាច្រើនផ្សេងទៀត ដូចជាកម្ពុជាជាដើមដែលកំពុងស្វែងរកកាលានុវត្តភាពក្នុងការបង្កើតឱ្យមានតុល្យភាពរវាងអាទិភាពនៃការអភិវឌ្ឍន៍និងការប្រែប្រួលអាកាសធាតុ។

1. Second National Forest Reference Level to the UNFCCC (2021).

2. Updated Nationally Determined Contribution (2020).

3. See: https://ncsd.moe.gov.kh/dcc/news/press-release-cambodia%E2%80%99s-updated-ndc-under-unfccc; https://ncsd.moe.gov.kh/resources/document/CambodiaNDCUpdated.

## ក្រាហ្វិកទី២៖ ការគ្រប់គ្រងព្រៃឈើ និងស្ថានភាពជីវចម្រុះនៅកម្ពុជា

**៧.៤លាន**
ហិកតា
**តំបន់ការពារធម្មជាតិ៖**
(៤១% នៃផ្ទៃដីប្រទេស)

**១៩លាន**
ហិកតា
**ព្រៃផ្តល់ផល៖**
(១០.៥% នៃផ្ទៃដីប្រទេស)

**១៦២** ប្រភេទ ថនិកសត្វ

**៦០១** ប្រភេទ សត្វស្លាប

**១៣៥៧** ប្រភេទ ត្រី

**៦៧១** ប្រភេទ សត្វឆ្អឹងខ្នង

**៣១១៣** ប្រភេទ រុក្ខជាតិ



© CAMBODIA RTS



© UNDP Cambodia



© CAMBODIA RTS

# ២. វឌ្ឍភាពទទួលបានរហូតមក ដល់ពេលនេះបានមកជាមួយ នឹងការចំណាយ



ព្រៃឈើមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការអភិវឌ្ឍន៍ដ៏ឆាប់រហ័សនៅកម្ពុជានាពេលថ្មីៗនេះ។ បន្ទាប់ពីឆ្លងកាត់ពីសង្គ្រាមនិងភាពក្រីក្រនៅក្នុងឆ្នាំ១៩៩៩មក កម្ពុជាកំពុងតែបោះជំហានឆ្ពោះទៅកាន់ប្រទេសជាតិមួយដែលមានប្រាក់ចំណូលជាមធ្យម។ ទោះជាយ៉ាងនេះក៏ដោយ វឌ្ឍនភាពទាំងនេះ ក៏បានបង្កផលប៉ះពាល់ដល់បរិស្ថានផងដែររួមទាំងការបាត់បង់គម្របព្រៃឈើយ៉ាងឆាប់រហ័ស ព្រោះថាដីព្រៃឈើមួយចំនួនត្រូវបានកាប់ឆ្ការដើម្បីយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងៗ។ ការសាងសង់ផ្លូវថ្នល់ឆ្លងកាត់តាមតំបន់ព្រៃឈើធម្មជាតិ ការកាប់ឆ្ការដីព្រៃឈើដើម្បីធ្វើកសិកម្ម និងសាងសង់លំនៅដ្ឋានជាដើម បានបង្កឱ្យមានការបាត់បង់ព្រៃឈើយ៉ាងច្រើន។ ដោយគ្មានជម្រើសថាមពលនានា តម្រូវការប្រើប្រាស់អុសនៅតែបន្តមាន ជាពិសេសនៅតំបន់ជនបទ ដែលមានប្រជាជន ៧៥% កំពុងរស់នៅ។[4] សមត្ថភាពក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅមានកម្រិតនៅឡើយ។

ភាពក្រីក្រនៅតែដើរតួនាទីសំខាន់ផងដែរ នៅពេលដែលប្រជាជនភាគច្រើននៅតំបន់ជនបទពឹងអាស្រ័យទៅលើធនធានព្រៃឈើសម្រាប់ការរស់នៅប្រចាំថ្ងៃ ព្រមទាំងម្ហូបអាហារ ថ្នាំសង្កូវ និងការសាងសង់ផ្ទះសម្បែងជាដើម។ កត្តាគំរាមកំហែងផ្សេងទៀតគឺចេញពីការអភិវឌ្ឍន៍នៅក្នុងតំបន់និងពិភពលោកលើតម្រូវការវត្ថុធាតុដើម ដែលព្រៃឈើនៅកម្ពុជានៅតែបន្តផ្គត់ផ្គង់។

ខណៈដែលព្រៃឈើកម្ពុជាជួយឲ្យមានការរីកចម្រើន ការបន្តការបាត់បង់ក៏គំរាមកំហែងដល់អនាគតរបស់ប្រទេសដែរ ជាពិសេសនៅក្នុងយុគសម័យនៃការប្រែប្រួលអាកាសធាតុ ដែលនឹងធ្វើឲ្យសេដ្ឋកិច្ចជាតិធ្លាក់ចុះប្រមាណជា១០% នៅឆ្នាំ២០៥០។[5] វិស័យសំខាន់ៗនៃសេដ្ឋកិច្ច រួមមានកសិកម្ម និងទេសចរណ៍ពឹងផ្អែកលើធនធានព្រៃឈើដែលនៅសេសសល់ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលព្រៃឈើបានផ្ដល់ឲ្យ។ ឧទាហរណ៍ព្រៃឈើការពារប្រជាជនពីគ្រោះទឹកជំនន់ ការបាក់ដី និងគ្រោះធម្មជាតិផ្សេងៗទៀត ហើយបន្ថែមពីនេះទៀតគឺរក្សាមិនឱ្យមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស។ ការគណនាមួយបង្ហាញថា អត្ថប្រយោជន៍សេដ្ឋកិច្ចពីព្រៃឈើដែលនៅសេសសល់មានផលចំណេញខ្ពស់ជាងការកាប់ឆ្ការព្រៃឈើសម្រាប់ការធ្វើកសិកម្មខ្នាតតូចនិងការផលិតធ្យូងចំនួនប្រាំដង។[6]

អត្ថប្រយោជន៍មួយចំនួនមិនត្រឹមតែមានសារៈសំខាន់ប៉ុណ្ណោះទេ វាថែមទាំងមានក្នុងរយៈពេលវែង និងមានការលំបាកនិងមើលឃើញណាស់ ទោះបីជាមានសម្ពាធប្រចាំថ្ងៃក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ដែលមានការកើនឡើងខ្លាំងក្នុងពេលដែលមានវិបត្តិសេដ្ឋកិច្ចបណ្ដាលមកពីការរីករាលដាលនៃជំងឺកូវីដ១៩ ក៏ដោយ។ មានការយល់ឃើញជាទូទៅថា ការអភិរក្សព្រៃឈើទាមទារឲ្យមានការចំណាយខ្ពស់ ដោយហេតុដូចនេះគេតែងតែពន្យាទុកចាំគិតគូរវានៅពេលក្រោយ។ មានផលប្រយោជន៍ហិរញ្ញវត្ថុច្រើនសន្ធឹកសន្ធាប់ ហាក់បីដូចជានៅតែបន្តទទួលបានពីការកាប់រានដីព្រៃឈើ ដើម្បីប្រើប្រាស់ដីសម្រាប់គោលបំណងផ្សេងទៀត។

តាមរយៈរេដបូក កម្ពុជាកំពុងស្វែងរកមធ្យោបាយ ដើម្បីធ្វើឱ្យមានតុល្យភាពរវាងអទិភាពប្រកួតប្រជែងគ្នាទាំងនេះ ព្រោះថាយន្តការនេះអាចកៀរគរថវិកាដើម្បីថែរក្សាព្រៃឈើនិងផ្ដល់ផលចំណេញដល់ការអភិវឌ្ឍន៍។ និយាយដោយខ្លី គឺការធ្វើឱ្យដើមឈើឈរមានតម្លៃជាងដើមឈើងាប់។

4. See: https://data.worldbank.org/indicator/SP.RUR.TOTL.ZS?locations=KH.

5. See: https://www.kh.undp.org/content/dam/cambodia/docs/ResearchAndPublication/CEGIM%20CC_Full%20report_EN_FA_1.pdf.

6. See: https://blogs.worldbank.org/eastasiapacific/valuing-ecosystem-services-provided-forests-pursat-basin-cambodia.


© CAMBODIA RTS


© CAMBODIA RTS

**ប្រអប់ទី១៖ តើនឹងមានអ្វីកើតឡើងនៅពេលដែលអ្នកកាប់ដើមឈើមួយដើម?**

ដើមឈើផ្ទុកដោយកាបូន។ ដើមឈើធំលូតលាស់បានដោយស្រូបឧស្ម័នកាបូនិកពីបរិយាកាសដើម្បីបង្កើតទៅជាដើម ស្លឹក ផ្លែ ឬស និងគល់។ នៅពេលដែលដើមឈើត្រូវបានកាប់ ឬដុតបំផ្លាញ ឬក៏រលួយពុកផុយនោះ វានឹងបញ្ចេញកាបូនទៅក្នុងបរិយាកាសវិញ។

នៅទូទាំងសកលលោក ការបាត់បង់ និងរេចរិលព្រៃឈើគឺជាកត្តាមួយដ៏ចំបងដែលធ្វើឲ្យមានការប្រែប្រួលអាកាសធាតុ ហើយវាបានបញ្ចេញកាបូនប្រមាណជា១៥% ទៅក្នុងបរិយាកាស។ ដើម និងស្លឹកឈើ រួមទាំងរុក្ខជាតិផ្សេងទៀតមានផ្ទុកកាបូនចំនួន៨០% នៅលើដី។ កាបូនប្រមាណ៤០% នៅក្រោមដី ផ្ទុកនៅក្នុងឬសឈើ និងនៅក្នុងដីក្រោមកម្រាលព្រៃឈើនោះ។[7]


© CAMBODIA RTS


© CAMBODIA RTS

7. See: https://www.forestcarbonpartnership.org/what-redd; What Is REDD book.

### ក្រាហ្វិកទី៣៖ ព្រៃឈើថយចុះដោយសារការប្រែប្រួលការប្រើប្រាស់ដី (ប្រភព៖ លេខាធិការដ្ឋានរេដបូក- ផែនការសកម្មភាពនិងថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ)




### ប្រអប់ទី២៖ ហេតុអ្វីបានជាព្រៃឈើបាត់បង់?

យុទ្ធសាស្ត្ររេដបូកជាតិបានកំណត់នូវបុព្វហេតុជាច្រើនក្នុងការផ្លាស់ប្តូរការប្រើប្រាស់ដីដែលបណ្តាលឲ្យបាត់បង់ព្រៃឈើ ហើយកត្តាទាំងនោះរួមមាន៖

១. លទ្ធភាពចូលទៅកាន់តំបន់ព្រៃឈើឆ្ងាយដាច់ស្រយាល មានភាពងាយស្រួលជាងមុន សកម្មភាពកាប់ឈើជាលក្ខណៈពាណិជ្ជកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកង្វះខាតលទ្ធភាពក្នុងការគ្រប់គ្រងធនធានព្រៃឈើនៅក្នុងតំបន់ទាំងនោះ។

២. ភាពមិនច្បាស់លាស់នៃសិទ្ធិប្រើប្រាស់ដី ការកើនឡើងតម្លៃដីធ្លី និងការទន្ទ្រានចាប់យកដីព្រៃឈើខុសច្បាប់។

៣. ការពង្រីកផ្ទៃដីកសិកម្មយ៉ាងឆាប់រហ័ស នៅក្នុងតំបន់ដីព្រៃឈើ ការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍកសិឧស្សាហកម្មទ្រង់ទ្រាយធំ និងការបែងចែកដីធ្លីក្រោមកម្មវិធីសម្បទានដីសង្គមកិច្ចពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ ២០១២។

៤. ការកាប់ឈើខុសច្បាប់ និងការដកហូតផលព្រៃឈើ និងអនុផលព្រៃឈើដោយគ្មាននិរន្តរភាព។

៥. អភិបាលកិច្ចព្រៃឈើ ការជម្រុញការអនុវត្តច្បាប់ ការពិនិត្យតាមដានព្រៃឈើនិងការប្រើប្រាស់ដី មិនទាន់មានប្រសិទ្ធភាព។

៦. តម្រូវការវត្ថុធាតុដើមដូចជាកៅស៊ូ និងស្ករអំពៅនៅក្នុងតំបន់និងពិភពលោកមានការកើនឡើង។

៧. ចំនួនប្រជាជនកើនឡើងស្របជាមួយនិងតម្រូវដីកសិកម្ម។

៨. ភាពក្រីក្រនៅជនបទ និងកង្វះជម្រើសសមស្របក្នុងការចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ។

៩. ការបំលាស់ទីចូលទៅរស់នៅក្នុងដីព្រៃឈើ ការអនុវត្តច្បាប់នៅមានកម្រិត ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមមិនទាន់គ្រប់គ្រាន់ កង្វះការចុះបញ្ជីដីរដ្ឋ និងការបោះបង្គោលព្រំដែនព្រៃឈើ។


© UNDP Cambodia


© CAMBODIA RTS

# ៣. រេដបូកៈមធ្យោបាយការពារ និរន្តរភាព និងកែលម្អរ គម្របព្រៃឈើ



គម្រោងរេដបូកបានបង្កើតនូវដំណោះស្រាយមួយសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍នានាក្នុងការទាញយកហិរញ្ញវត្ថុដែលអាចជួយសម្រេចគោលដៅការពារបរិស្ថាននិងការប្រែប្រួលអាកាសធាតុបាន។ ប្រភពហិរញ្ញវត្ថុនេះគឺបានមកពីបណ្តាប្រទេសឧស្សាហកម្ម អង្គការពហុភាគី និងក្រុមហ៊ុនឯកជននានានៅទូទាំងពិភពលោក។ ស្ថាប័នទាំងនេះផ្តល់ហិរញ្ញវត្ថុដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីអភិរក្សនិងបង្កើនស្តុកកាបូននៅក្នុងព្រៃឈើ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលពីការបាត់បង់និងការរេចរិលព្រៃឈើ។

គំនិតផ្តួចផ្តើមរេដបូកនេះ អាចធ្វើទៅបានទាំងនៅថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ។ ការងារនេះអាចរួមបញ្ចូលការពង្រឹងការអនុវត្តច្បាប់ និងការអភិរក្សដែលល្អប្រសើរជាងមុន ការពង្រឹងប្រព័ន្ធពិនិត្យតាមដានព្រៃឈើ ការបង្កើនតំបន់ការពារធម្មជាតិ ការគ្រប់គ្រងភ្លើងឆេះព្រៃប្រកបដោយប្រសិទ្ធភាព ការបញ្ឈប់ការកាប់ព្រៃឈើដែលគ្មាននិរន្តរភាព និងការលើកកម្ពស់ការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាព។ ការអភិវឌ្ឍន៍រេដបូកមានបីដំណាក់កាល៖ ដំណាក់កាលត្រៀមខ្លួន ដំណាក់កាលអនុវត្ត និងដំណាក់កាលទូទាត់ដោយផ្អែកលើលទ្ធផលក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមរយៈសកម្មភាពព្រៃឈើ។

មានកម្មវិធីផ្សេងៗគ្នាជាច្រើនដែលជួយឲ្យបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ចាប់ផ្តើមរៀបចំដំណើរការអនុវត្តគម្រោងរេដបូក។ កម្មវិធីទាំងនោះរួមមាន កម្មវិធីភាពជាដៃគូកាបូនព្រៃឈើ កម្មវិធីភាពជាដៃគូសកលរដ្ឋាភិបាល ក្រុមហ៊ុនឯកជន សង្គមស៊ីវិល ជនជាតិដើមភាគតិច និងកម្មវិធីរេដបូកក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឬ UNFCCC ។ មូលនិធិអាកាសធាតុបៃតងបានក្លាយជាប្រភពហិរញ្ញវត្ថុពហុភាគីមួយដ៏សំខាន់ ដើម្បីផ្តល់ការទូទាត់ដោយផ្អែកលើលទ្ធផលរេដបូក។ តាមរយៈទីផ្សារកាបូនស្ម័គ្រចិត្ត ក្រុមហ៊ុនឯកជនជាច្រើនបានទិញឥណទានកាបូនពីគម្រោងគ្រប់គ្រងព្រៃឈើនានា។ ឥណទានកាបូនទាំងនេះបានជួយដល់គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ពួកគេ ហើយផ្តល់ហិរញ្ញវត្ថុគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការអភិរក្សព្រៃឈើ។



© CAMBODIA RTS

## តើគម្រោងរេដបូកកើតចេញមកពីណា ?

គម្រោងរេដបូកបានកើតចេញពីកិច្ចព្រមព្រៀងជាសកលជាបន្តបន្ទាប់ ចាប់តាំងពីឆ្នាំ២០០៥មក ជាមួយនិងការរៀបចំសន្និសិទនៃបណ្តាភាគីអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ១៩៩២។ គំនិតផ្តួចផ្តើមជុំវិញការកាត់បន្ថយការបាត់បង់និងការរេចរិលព្រៃឈើត្រូវបានបង្កើតឡើង ហើយរេដបូកក៏បានអនុម័តដោយគ្រប់សមាជិកទាំងអស់នៅក្នុងសន្និសិទទីក្រុងបាលីក្នុងឆ្នាំ២០០៧ ដោយបានទទួលស្គាល់ថាតាមរយៈការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព បណ្តាប្រទេសកំពុងអភិវឌ្ឍន៍អាចការពារមិនឲ្យមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាសបាន។ នៅឆ្នាំ២០១៣ ភាគីទាំងអស់បានអនុម័តលើក្របខណ្ឌវ៉ារស្សូវីសម្រាប់រេដបូក ដើម្បីផ្តល់ជាការណែនាំនិងហិរញ្ញវត្ថុគាំទ្រដល់ការអនុវត្តកម្មវិធីរេដបូក ដោយផ្តោតសំខាន់លើការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ឆ្នាំ២០១៥ បានគាំទ្រដល់រេដបូក។ បណ្តាប្រទេសឧស្សាហកម្មជាច្រើន ដែលបានរួមចំណែកបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាសច្រើនជាងគេ បានប្តេជ្ញាចិត្តគាំទ្រដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការចាត់វិធានការសមស្របលើការប្រែប្រួលអាកាសធាតុ។ កិច្ចសន្យានេះរួមបញ្ចូលទាំងការផ្តល់ហិរញ្ញប្បទានអាកាសធាតុឲ្យបានគ្រប់គ្រាន់ផងដែរ។ ការរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDCs) តម្រូវឲ្យគ្រប់ភាគីនៃកិច្ចព្រមព្រៀង កំណត់គោលដៅអាកាសធាតុ និងតម្រូវការធនធាន ដើម្បីអនុវត្តគោលដៅនោះ រួមទាំងតាមរយៈរេដបូកផងដែរ។



© CAMBODIA RTS

### ប្រអប់ទី៣៖ ហេតុអ្វី + នៅក្នុងរេដ ?

នៅឆ្នាំ ១៩៩០ គំនិតផ្តួចផ្តើម រេដ ត្រូវបានបង្កើតឡើង។ គំនិតនេះផ្តោតលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពសំខាន់ៗចំនួនពីរដែលបណ្តាលឲ្យបាត់បង់ព្រៃឈើ៖ ការបាត់បង់ និងការរេចរិលព្រៃឈើ។ ប៉ុន្តែគំនិតនេះចេះតែបន្តវិវត្តទៅមុខ បន្ទាប់ពីមានកិច្ចពិភាក្សាជាលក្ខណៈអន្តរជាតិអស់រយៈពេលជាច្រើនឆ្នាំមក។ រេដបូករួមបញ្ចូលសកម្មភាពបីបន្ថែមទៀត៖ ការអភិរក្សស្តុកកាបូនព្រៃឈើ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងការបង្កើនស្តុកកាបូនព្រៃឈើ។ រេដបូកបានក្លាយជាយន្តការសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពទាំង៥នេះ ដើម្បីការពារនិងអភិរក្សព្រៃឈើត្រូពិក។

### ក្រាហ្វិកទី៤៖ ការកាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើ (រេដបូក)






# ៤. កម្ពុជាត្រៀមខ្លួនរួចជាស្រេចសម្រាប់រេដបូក



នៅទូទាំងពិភពលោក កម្ពុជាគឺជាប្រទេសដែលចាប់ផ្តើមរេដបូកមុនគេ។ រាជរដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីព្រៃឈើ ចាប់តាំងពីឆ្នាំ២០០២ មុនពេលដែលរេដបូកត្រូវបានចាប់ផ្តើមជាផ្លូវការជាលក្ខណៈអន្តរជាតិនៅឆ្នាំ២០០៧។ ច្បាប់ស្តីពីព្រៃឈើនៅឆ្នាំ២០០២ បានផ្តល់នូវក្របខណ្ឌរួមមួយ ដើម្បីបង្កើតព្រៃការពារនិងសហគមន៍ព្រៃឈើ។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ បានបង្កើតជាមូលដ្ឋានគ្រឹះ សម្រាប់ការបង្កើតឧទ្យានជាតិថ្មី និងរបៀងអភិរក្សជីវចម្រុះ។ នៅឆ្នាំ ២០១៨ ផ្ទៃដីតំបន់ការពារធម្មជាតិបានកើនឡើងដល់ជាង៤១% គឺកើនឡើងពី១៨%ក្នុងឆ្នាំ១៩៩៣។

ទោះបីជាសម្រេចបានសមិទ្ធផលផ្នែកច្បាប់ច្រើនយ៉ាងណាក៏ដោយ ក៏កម្ពុជានៅតែជួបប្រទះបញ្ហាប្រឈម ក្នុងកៀរគរធនធានឲ្យបានគ្រប់គ្រាន់ សម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពការពារនៅថ្នាក់មូលដ្ឋាន។[8] ការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅតែរីករាលដាល និងពិបាកនឹងបញ្ឈប់។ ការដោះស្រាយបញ្ហានេះ ទាមទារឲ្យមានការពង្រីកការវិនិយោគទ្រង់ទ្រាយធំ លើវិធានការសមស្របមួយចំនួនដូចជាការបញ្ជាក់ពីសិទ្ធកាន់កាប់ដីធ្លី ការកែលម្អជីវភាពសហគមន៍ ការលើកកម្ពស់ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពនិងការពិនិត្យតាមដានជាប្រចាំ។

រាជរដ្ឋាភិបាលមើលឃើញថារេដបូក គឺជាឱកាសមួយដ៏ល្អក្នុងការកៀរគរធនធានថ្មី។ នៅក្នុងឆ្នាំ២០១៧ រាជរដ្ឋាភិបាលបានអនុម័តយុទ្ធសាស្ត្ររេដបូកជាតិ ២០១៧-២០២៦។ ដោយមានការគាំទ្រពីដៃគូអន្តរជាតិជាច្រើន រាជរដ្ឋាភិបាលរំពឹងថានឹងជួយទប់ស្កាត់បញ្ហានៃការបាត់បង់ព្រៃឈើនិងជីវៈចម្រុះដ៏គួរឱ្យព្រួយបារម្ភណ៍ខណៈដែលរក្សាបាននូវផលចំណេញពីការអភិវឌ្ឍន៍ ដល់ប្រជាជនដែលពឹងអាស្រ័យលើព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត និងប្រភពធនធានផ្សេងៗទៀត។



© CAMBODIA RTS

8. https://www.ecosystemmarketplace.com/articles/cambodia-embarks-on-building-a-nested-system-to-protect-remaining-forests/





ដើម្បីត្រៀមខ្លួនឱ្យបានរួចជាស្រេច សម្រាប់រេដបូក រាជរដ្ឋាភិបាលបានបង្កើតផែនទីបង្ហាញផ្លូវស្តីពីរេដបូក។ ផែនទីនោះបានកំណត់នូវសមាសធាតុនានា ដែលនឹងធ្វើឱ្យកម្មវិធីរេដបូកមានភាពរឹងមាំ និងអាចទុកចិត្តបាន ទាក់ទាញដល់ការគាំទ្រហិរញ្ញវត្ថុ។ ទាំងនេះរួមបញ្ចូលទាំងការរៀបចំយុទ្ធសាស្ត្រជាតិបានយ៉ាងល្អ សមត្ថភាពគ្រប់គ្រងឱ្យកាន់តែប្រសើរ ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ដែលរងផលប៉ះពាល់ដោយសារការធ្វើសេចក្តីសម្រេចចិត្តស្តីពីព្រៃឈើ ក្របខ័ណ្ឌសម្រាប់ការបែងចែកផលប្រយោជន៍ និងការធានាសុវត្ថិភាព និងប្រព័ន្ធវាស់វែង និងពិនិត្យតាមដានការអនុវត្តផងដែរ។

ការរៀបចំចាប់ផ្តើមដំណើរការរេដបូក ពាក់ព័ន្ធនឹងការបង្កើតក្រុមការងាររេដបូក និងក្រុមបច្ចេកទេស រួមជាមួយនឹងក្រុមប្រឹក្សាយោបល់ និងក្រុមយេនឌ័រ ដើម្បីលើកកម្ពស់ការពិគ្រោះយោបល់ទូលំទូលាយ និងបញ្ជ្រាបយេនឌ័រនៅគ្រប់ដំណើរការនៃការរៀបចំការអនុវត្តរេដបូក។ យុទ្ធសាស្ត្រទំនាក់ទំនងក៏បានលើកកម្ពស់ការយល់ដឹងពីរេដបូកដល់អ្នកពាក់ព័ន្ធ ហើយនៅឆ្នាំ ២០១៣ រាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើកំណែទម្រង់អភិបាលកិច្ចការគ្រប់គ្រងព្រៃឈើ និងបរិស្ថាន។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព ដែលបានបង្កើតឡើងនៅឆ្នាំ២០១៥ ត្រូវបានចាត់តាំងជាប្រធានក្រុមការងាររេដបូក និងសម្របសម្រួលដល់ការធ្វើសេចក្តីសម្រេចចិត្តនៅទូទាំងក្រសួងស្ថាប័នផ្សេងៗគ្នា ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដើម្បីផ្សារភ្ជាប់ទំនាក់ទំនងបញ្ហាសេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍ។

ក្នុងឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានឯកភាពផ្លាស់ប្តូរការគ្រប់គ្រងតំបន់អភិរក្សទាំងអស់ទៅឲ្យក្រសួងបរិស្ថាន ដែលជាចំណាត់ការមួយដ៏សំខាន់ នាំឲ្យមានការផ្ទេរព្រៃការពារចំនួន ១លាន ៦សែនហិកតា ពីរដ្ឋបាលព្រៃឈើ ទៅក្រសួងបរិស្ថាន។ ផ្ទៃដីតំបន់ការពារបានកើនឡើងពី១៨%នាឆ្នាំ១៩៩៣ ទៅជាង៤១% នៅឆ្នាំ២០១៨ ។



© CAMBODIA RTS

ក្រុមបរិស្ថាន និងធនធានធម្មជាតិត្រូវបានបង្កើតឡើង ដើម្បីកំណត់ក្របខ័ណ្ឌច្បាប់សម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមត្រូវបានណែនាំ ដើម្បីបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីសកម្មភាពអភិវឌ្ឍន៍នានា។

## ប្រអប់ទី៤៖ រេដបូកនៅមូលដ្ឋាន

កម្ពុជាបានអនុវត្តគម្រោងរេដបូក សាកល្បងដំបូងគេបង្អស់ ក្នុងចំណោមគម្រោងមួយចំនួនរបស់ពិភពលោក។ ជាឧទាហរណ៍ ព្រៃការពារកែវសីមា បានវិវត្តន៍ឈានទៅសម្រេចលក់ឥណទានកាបូនបានដោយជោគជ័យនៅក្នុងទីផ្សារកាបូនស្ម័គ្រចិត្ត។ ចំណូលពីការលក់ឥណទានកាបូនទាំងនេះ បានផ្តល់ហិរញ្ញប្បទានគាំទ្រដល់ការការពារដែនជម្រកសត្វព្រៃកែវសីមា និងសហគមន៍ដែលនៅជុំវិញនោះ រួមទាំងការអភិវឌ្ឍន៍ជីវភាពសហគមន៍ ការរៀបចំផែនការប្រើប្រាស់ដី និងការកែលម្អការគ្រប់គ្រងព្រៃឈើ។

នៅឆ្នាំ២០២០ ប្រទេសកម្ពុជាបានប្រមូលថវិកាបានជាង ១១លានដុល្លារអាមេរិកពីបណ្តាក្រុមហ៊ុនឯកជន នានានៅអឺរ៉ុប ជប៉ុន និងសហរដ្ឋអាមេរិក សម្រាប់គម្រោងអភិរក្សព្រៃឈើចំនួនបី។[9] ក្រៅពីដែនជម្រកសត្វព្រៃកែវសីមា នៅមានគម្រោងដែនជម្រកសត្វព្រៃជួរភ្នំក្រវាញភាគខាងត្បូង និងដែនជម្រកសត្វព្រៃតាតៃ។

តាមរយៈកម្មវិធីរេដបូកអង្គការសហប្រជាជាតិ (UN-REDD) និងកម្មវិធីជំនួយខ្នាតតូចមូលនិធិបរិស្ថានសកល សហគមន៍បានអនុវត្តគម្រោងសាកល្បងជាច្រើន ដូចជាការប្រើប្រាស់គម្រោងជំនួយខ្នាតតូច ដើម្បីទិញបន្ទះសូឡាដែលស្រូបពន្លឺព្រះអាទិត្យ ដើម្បីសាកអាគុយជាដើម។ សមាជិកសហគមន៍គ្រាន់តែ បង់ថ្លៃសេវាតិចតួចដើម្បីសាកអាគុយរបស់ខ្លួនតែប៉ុណ្ណោះ។ ថវិកាដែលបានពីសេវាកម្មនេះ ត្រូវបានបញ្ចូលទៅក្នុងមូលនិធិសហគមន៍ ដើម្បីគាំទ្រដល់ការចុះល្បាតព្រៃនៅក្នុងតំបន់សហគមន៍របស់ពួកគេ។

បទពិសោធន៍ទាំងនេះបានជំរុញឱ្យមានសន្ទុះ ក្នុងការរៀបចំគម្រោងរេដបូក និងបានកសាងឃ្លាំងចំណេះដឹងក្នុងការគ្រប់គ្រងតំបន់ទេសភាពសំខាន់ៗ ដូចជាតំបន់ព្រៃលិចទឹក និងព្រៃកោងកាង ជាដើម។ តំបន់ទាំងពីរនេះ គឺជាប្រភពអាហារ និងប្រាក់ចំណូលដ៏សំខាន់សម្រាប់សហគមន៍មូលដ្ឋាន ព្រមទាំងអាចស្រូបស្តុកកាបូនមិនឱ្យបញ្ចេញទៅបរិយាកាសក្នុងអត្រាខ្ពស់បានផងដែរ។ នៅពេលដែលរាជរដ្ឋាភិបាលជំរុញដល់ការអនុវត្តរបៀបវារៈគោលនយោបាយជាតិវាបានទាក់ទាញការពិគ្រោះយោបល់ជាទៀងទាត់ជាមួយអ្នកពាក់ព័ន្ធ រួមទាំងពីសហគមន៍មូលដ្ឋាន ដើម្បីរៀនពីការយល់ដឹងរបស់ពួកគេ និងដំណោះស្រាយជាក់ស្តែងជាច្រើនផងដែរ។

**Sources:**

https://www.terraglobalcapital.com/oddar-meanchey-community-redd-project-cambodia
https://www.vcsprojectdatabase.org/#/project_details/1650
https://www.vcsprojectdatabase.org/#/project_details/1748
https://www.vcsprojectdatabase.org/#/project_details/1689
https://www.jcm.go.jp/kh-jp/methodologies/97

**9.** https://www.ecosystemmarketplace.com/articles/cambodia-embarks-on-building-a-nested-system-to-protect-remaining-forests/, https://www.phnompenhpost.com/national/increase-carbon-credit-sales-sought.








ក្រាហ្វិកទី៥៖ ដំណើររបស់កម្ពុជាឆ្ពោះទៅបង្កើតកម្មវិធីរេដបូក






# ៥. ការរៀបចំសសរស្តម្ភរេដបូក



កិច្ចប្រឹងប្រែងដំបូងរបស់កម្ពុជា ដើម្បីត្រៀមខ្លួនសម្រាប់ការអនុវត្តរេដបូក បានចាប់ផ្តើមឡើង ជាពិសេសបន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតា ក្នុងការត្រៀមខ្លួនឱ្យបានរួចស្រេចសម្រាប់ការអនុវត្តរេដបូកចាប់ពីឆ្នាំ២០២១ទៅ។ ចាប់ផ្តើមតាំងពីឆ្នាំ២០១៧មក វឌ្ឍនភាពសម្រេចបានតាមរយៈការរៀបចំសសរស្តម្ភសំខាន់ៗចំនួនបួន ដែលជាមូលដ្ឋានគ្រឹះសម្រាប់ភាពជោគជ័យកនៃការអនុវត្តរេដបូក។ សសរស្តម្ភសំខាន់ៗទាំងនោះតម្រង់ទិសដល់ការធ្វើផែនការ ការវាស់វែង ការពិនិត្យតាមដាន និងការធានាសុវត្ថិភាព (សូមមើលគំនូសតាងលេខ២)។

ក្រាហ្វិកទី៦៖ រេដបូករៀបចំឡើងផ្អែកលើសសរស្តម្ភសំខាន់ៗ ចំនួន៤




សសរស្តម្ភទី១គឺយុទ្ធសាស្ត្ររេដបូកជាតិ ដែលបានអនុម័ត ក្នុងឆ្នាំ២០១៧ ។ យុទ្ធសាស្ត្រនេះបានរៀបរាប់យ៉ាងពិស្តារអំពីបុព្វហេតុចម្បងៗ នៃការបាត់បង់ព្រៃឈើនិងការរេចរឹលព្រៃឈើ ហើយបានដាក់ចេញនូវវិធានការនានា ដើម្បីដោះស្រាយការខូចខាត កែលម្អគម្របព្រៃឈើ និងរួមចំណែកដល់ការអភិវឌ្ឍដោយចីរភាព។






### ប្រអប់ទី៥៖ យុទ្ធសាស្ត្ររេដបូកជាតិ

គោលបំណង៖ កាត់បន្ថយការបាត់បង់ និងការរេចរឹលព្រៃឈើ លើកកម្ពស់ការគ្រប់គ្រងប្រកបដោយនិរន្តរភាព ការអភិរក្សធនធានធម្មជាតិ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ដើម្បីដោះស្រាយបុព្វហេតុចម្បងៗ ទាំងផ្ទាល់ ទាំងប្រយោល ដែលបណ្តាលឱ្យមានការបាត់បង់និងការរេចរឹលព្រៃឈើ យុទ្ធសាស្ត្ររេដបូកជាតិបានកំណត់ទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗ ចំនួន៣ រួមមាន៖

១. កែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រង និងការពិនិត្យតាមដានធនធានព្រៃឈើ និងការប្រើប្រាស់ដីព្រៃឈើ
២. ពង្រឹងការអនុវត្តសកម្មភាពគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និង
៣. បញ្ជ្រាបវិធីសាស្ត្រកាត់បន្ថយការបាត់បង់ព្រៃឈើ បង្កើនសមត្ថភាព និងលើកកម្ពស់ការចូលរួមពីអ្នកពាក់ព័ន្ធ។

ការប្រែប្រួលដែលកើតចេញពីការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិ៖

- អភិរក្សព្រៃឈើធម្មជាតិដែលនៅសេសសល់ និងការកើនឡើងនៃសន្និធិកាបូនក្នុងព្រៃឈើ។
- ការលើកកម្ពស់ជីវភាពប្រជាជននៅមូលដ្ឋានប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងសិទ្ធិអំណាចរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានព្រៃឈើ។
- ការអនុវត្តគម្រោងរេដបូកតាមរយៈការសម្របសម្រួលអន្តរវិស័យនិងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

នៅឆ្នាំ២០១៧ ដដែលនោះ របាយការណ៍ទី១ ស្តីពីការរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ បានចែងថាព្រៃឈើនឹងក្លាយជាអាទិភាពសំខាន់ ក្នុងការកាត់បន្ថយ និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ របាយការណ៍នេះ បានកំណត់សកម្មភាពព្រៃឈើពាក់ព័ន្ធនានាទាក់ទងនឹងការផលិតថាមពល ការផលិតទំនិញ ការដឹកជញ្ជូន ការគ្រប់គ្រងសំណល់ និងការប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់ប្រព័ន្ធធារាសាស្ត្រនិងចង្កៀងប្រើពន្លឺព្រះអាទិត្យ។ របាយការណ៍នេះបានចង្អុលបង្ហាញពីរេដបូកដែលមានទំនាក់ទំនងជាពិសេសជាមួយព្រៃឈើ អាចជួយដល់ការសម្រេចគោលដៅវិស័យផ្សេងៗនៃសេដ្ឋកិច្ចបាន។

យុទ្ធសាស្ត្ររេដបូកជាតិរៀបចំឡើង ដោយផ្អែកលើគោលនយោបាយជាតិ សម្រាប់ការគ្រប់គ្រងធនធានព្រៃឈើ។ យុទ្ធសាស្ត្រនេះទប់ទល់នឹងសម្ពាធលើព្រៃឈើតាមរយៈការធ្វើផែនការប្រើប្រាស់ដីនិងការគ្រប់គ្រងធនធានធម្មជាតិឱ្យកាន់តែប្រសើរ ហើយបានបង្កើនសមត្ថភាពសម្រាប់ពិនិត្យតាមដាននិងពង្រឹងការអនុវត្តបទប្បញ្ញត្តិនានា។ យុទ្ធសាស្ត្រនេះលើកកម្ពស់សកម្មភាពគ្រប់គ្រងព្រៃឈើ ជីវភាពប្រជាជន និងការវិនិយោគដោយវិស័យឯកជន ឱ្យកាន់តែមាន

និរន្តរភាពបន្ថែមទៀត។ វាកំណត់កាន់តែច្បាស់ឡើងនូវវិធាននានាជុំវិញការកាន់កាប់ដីធ្លី គំរូកសិកម្មប្រកបដោយនិរន្តរភាព និងប្រភពថាមពលកកើតឡើងវិញ។

ការអនុវត្តយុទ្ធសាស្ត្ររេដបូកជាតិបានពេញលេញនឹងមានន័យថា កម្ពុជាអាចអភិរក្សព្រៃឈើធម្មជាតិ ដែលនៅសេសសល់បានផង និងអាចបង្កើនសមត្ថភាពស្តុកនិងស្រូបយកកាបូនបានផង ហើយសហគមន៍នឹងអាចប្រើប្រាស់ធនធានទាំងនោះ ដោយមិនប៉ះពាល់ដល់បរិស្ថាន។ ការចូលរួមយ៉ាងជិតដល់ពីសហគមន៍ក្នុងការគ្រប់គ្រងធនធានព្រៃឈើនឹងបង្កើនការចូលរួមពីសង្គម លើកកម្ពស់សមភាពយេនឌ័រ ដែលកត្តាទាំងពីរបានគូសបញ្ជាក់យ៉ាងសំខាន់នៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិផងដែរ។

សសរស្តម្ភសំខាន់ទី២គឺការវាយតម្លៃហៅថាកម្រិតយោងព្រៃឈើ ។ ប្រទេសកម្ពុជាបានដាក់កម្រិតយោងព្រៃឈើជាតិលើកទី១ទៅក្របខណ្ឌអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅឆ្នាំ២០១៧ ដោយប្រើប្រាស់ទិន្នន័យគម្របព្រៃឈើឆ្នាំ២០០៦ដល់ឆ្នាំ២០១៤។ នៅឆ្នាំ២០២១ កម្រិតយោងព្រៃឈើជាតិលើកទី២ ដែលប្រើប្រាស់ទិន្នន័យគម្របព្រៃឈើឆ្នាំ២០១០ដល់ឆ្នាំ២០១៨ បានកត់ត្រាការបញ្ចេញកាបូនពីការបាត់បង់ព្រៃឈើ និងការស្រូបកាបូន តាមរយៈការពង្រឹងការអនុវត្តនិងការគ្រប់គ្រងព្រៃឈើ។ កម្រិតយោងព្រៃឈើទីពីរនេះបានព្យាករណ៍លទ្ធផលនៃការអនុវត្តសកម្មភាពរេដបូក ដោយប្រៀបធៀបទៅនឹងកម្រិតយោងព្រៃឈើលើកទី១។ នៅត្រឹមឆ្នាំ២០២១ លទ្ធផលបានបង្ហាញថា ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើបានថយចុះ អំឡុងឆ្នាំ២០១៥-២០១៦ និងអំឡុងឆ្នាំ២០១៧-២០១៨ បើធៀបទៅនឹងអំឡុងឆ្នាំ២០០៦-២០១៤។

សសរស្តម្ភសំខាន់ទី៣គឺ ប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ ដែលប្រទេសកម្ពុជាបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៧ សម្រាប់តាមដានការអនុវត្តសកម្មភាពរេដបូក ព្រមទាំងសម្រាប់កែលម្អទិន្នន័យស្តីពីសន្និធិកាបូនក្នុងព្រៃឈើ និងការផ្លាស់ប្តូរគម្របព្រៃឈើ។ ប្រព័ន្ធនេះបានអនុម័តនិយមន័យព្រៃឈើជាតិនិងប្រព័ន្ធបែងចែកចំណាត់ថ្នាក់ការប្រើប្រាស់ដី ព្រមទាំងបានរៀបចំឧបករណ៍ពិនិត្យតាមដានពីលើអាកាស ដោយផ្អែកលើកម្មវិធីហ្គូហ្គលអ៊ើដ (Google Earth) ដើម្បីប្រកាសអាសន្នពីការបាត់បង់ព្រៃឈើនៅទូទាំងពិភពលោក។ បច្ចុប្បន្ននៅកម្ពុជា ប្រព័ន្ធនេះបាននឹងកំពុងធ្វើការរៀបចំដើម្បីផ្តល់ដំណឹង និងព័ត៌មានស្តីពីការបាត់បង់ព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ។

សសរស្តម្ភសំខាន់ទី៤ នៃរេដបូកគឺប្រព័ន្ធព័ត៌មានធានាសុវត្ថិភាព ដែលបានផ្សព្វផ្សាយដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០១៩។ ប្រព័ន្ធនេះតម្រូវឱ្យមានការពិនិត្យតាមដានជាប្រចាំនូវការគោរព និងដោះស្រាយគោលការណ៍សុវត្ថិភាព សង្គមនិងបរិស្ថានទាំង៧ ដែលអនុវត្តលើគម្រោងរេដបូកទាំងអស់។ ឧទាហរណ៍មានដូចជាការធានាតម្លាភាពក្នុងអភិបាលកិច្ចព្រៃឈើ ការលើកកម្ពស់ឱ្យបានពេញលេញនូវសិទ្ធិរបស់សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច។ ប្រព័ន្ធនេះអាចឱ្យយើងមើលឃើញនូវហានិភ័យ និងផលប៉ះពាល់នានាដែលកើតចេញពីសកម្មភាពរេដបូក ហើយសកម្មភាពដែលត្រូវធ្វើដើម្បីបន្ធូរបន្ថយ និងគ្រប់គ្រងហានីភ័យនិងផលប៉ះពាល់ទាំងនោះ។

នៅឆ្នាំ២០២១ ផែនការសកម្មភាពនិងថវិកានៃយុទ្ធសាស្ត្ររេដបូកជាតិ ព្យាករណ៍ថវិកាសរុបប្រមាណ ១៨៦លានដុល្លារសម្រាប់អនុវត្តយុទ្ធសាស្ត្ររេដបូកជាតិរហូតដល់ឆ្នាំ២០៣០ ត្រូវបានអនុម័ត។ ផែនការនេះសម្របសម្រួលការកៀរគរធនធាននិងការវិនិយោគស្របតាមយុទ្ធសាស្ត្រនិងការប្តេជ្ញារបស់កម្ពុជាក្នុងការរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ការវិភាគបែបសេដ្ឋកិច្ច សម្រាប់ការរៀបចំផែនការនេះ បានបង្ហាញឱ្យឃើញថា រេដបូកអាចជួយទប់ស្កាត់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើ ព្រមទាំងអាចថែរក្សាសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងផ្តល់ផលប្រយោជន៍ ទាក់ទងកាបូន និង មិនទាក់ទងកាបូនច្រើនជាង បើធៀបទៅនឹងព្រៃឈើដែលពុំមានគម្រោងរេដបូក។ ផែនការនេះអាចជួយសន្សំកាបូនបានប្រមាណ៣៦០មេហ្គាតោន ដែលមានតម្លៃប្រហែល១,៨ពាន់លានដុល្លារនៅលើទីផ្សារអន្តរជាតិ។[10]

10. At $5 per ton of $CO_2e$.





ក្រាហ្វិកទី៧៖ រេដបូកអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឱ្យធ្លាក់ចុះ




ជាផ្នែកមួយនៃការប្រតិបត្តិផែនការសកម្មភាពនិងថវិកាសម្រាប់ការអនុវត្តយុទ្ធសាស្ត្ររេដបូក កម្ពុជាបានចែងច្បាស់លាស់អំពីអាណត្តិរបស់ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងបានដាក់ចេញគោលការណ៍ណែនាំសម្រាប់ការសម្របសម្រួលការអនុវត្ត ការពិនិត្យតាមដាន និងការរាយការណ៍។ នៅថ្នាក់ជាតិ ក្រសួងបរិស្ថានមានភារកិច្ចទទួលខុសត្រូវរួមសម្រាប់រេដបូក ដោយធ្វើការជាមួយក្រុមការងាររេដបូក និងផ្នែកគោលនយោបាយ ផ្នែកវាស់វែងនិងរបាយការណ៍ ផ្នែកប្រព័ន្ធធានាសុវត្ថិភាព និងផ្នែកពិនិត្យតាមដាននិងវាយតម្លៃ។ ក្រុមប្រឹក្សាយោបល់រេដបូកមានភារកិច្ចរក្សាទំនាក់ទំនងទៀងទាត់ជាមួយអង្គការមិនមែនរដ្ឋាភិបាល សហគមន៍នានាដែលពឹងអាស្រ័យនឹងព្រៃឈើ និងបណ្តាក្រុមហ៊ុនដែលពាក់ព័ន្ធនឹងវិស័យកសិកម្មជាអាទិ៍ក្នុងចំណោមក្រុមហ៊ុនផ្សេងៗទៀត ព្រមទាំង ក្រុមយេនឌ័រផ្តោតការយកចិត្តទុកដាក់ចំពោះសមភាពយេនឌ័រ។ នៅថ្នាក់ក្រោមជាតិ រដ្ឋបាលខេត្តនិងរដ្ឋបាលស្រុកគ្រប់គ្រងនិងសម្របសម្រួលការអនុវត្តរេដបូកក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដៃគូអនុវត្តន៍ឯទៀតៗ ពីស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាសហគមន៍មូលដ្ឋាន ជាអ្នកចូលរួមអនុវត្តគម្រោងរេដបូក។

### ប្រអប់ទី៦៖ ការចាត់ចែងមូលនិធិសម្រាប់អភិរក្ស

ប្រភពហិរញ្ញវត្ថុចម្បងរបស់កម្ពុជា សម្រាប់គាំទ្រដល់ការអនុវត្តគម្រោងអាកាសធាតុនិងបរិស្ថាន រួមមានប្រភពថវិកាមកពីរាជរដ្ឋាភិបាល ជំនួយអភិវឌ្ឍន៍ផ្លូវការ រេដបូក គម្រោងបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី មូលនិធិបរិស្ថាននិងសង្គម មូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ និងពន្ធ ប្រាក់ឈ្នួល សួយសារ និងការបង់ថ្លៃផ្សេងៗទៀត។

ការចំណាយសម្រាប់ការអភិរក្សព្រៃឈើនិងជីវចម្រុះ ក្នុងឆ្នាំ២០១៨ បានកើនឡើងដល់១១២លានដុល្លារ ប៉ុន្តែតម្រូវការត្រូវបានប៉ាន់ប្រមាណថាមានចំនួនជាង៣០៥លានដុល្លារ ជាហេតុនាំឱ្យមានកង្វះខាតហិរញ្ញប្បទានដល់ទៅ ១៩៥លានដុល្លារ។

វិធីដោះស្រាយបញ្ហាហិរញ្ញប្បទានរួមមាន៖

ឥណទានកាបូន៖ នៅឆ្នាំ២០២០ រេដបូករកចំណូលបានជាង១១,៦លានដុល្លារ តាមរយៈការលក់ឥណទានកាបូននៅក្នុងទីផ្សារកាបូនស្ម័គ្រចិត្ត។

ទេសចរណ៍ធម្មជាតិនៅតំបន់ការពារ៖ វិស័យនេះបានផ្តល់ចំណូលជាង២៥លានដុល្លារ ក្នុងឆ្នាំ ២០២០។

ការអនុវត្តសាកល្បងគម្រោងបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី៖ គម្រោងនៅតំបន់ប្រើប្រាស់ច្រើនយ៉ាងក្បាលឆាយ និងនៅឧទ្យានជាតិភ្នំគូលែន អាចរកចំណូលបានជាង៥លានដុល្លារ ក្នុងមួយឆ្នាំ។


© CAMBODIA RTS


© CAMBODIA RTS

# ៦. សុខដុមនីយកម្មបដិបត្តិ
# រេដបូកឬការផ្តល់ឥណទាន
# ទៅកន្លែងដែលសមទទួលបាន



ប្រទេសកម្ពុជាបានឈានដល់ដំណាក់កាលឈានមុខគេក្នុងដំណើរអនុវត្តកម្មវិធីរេដបូក។ យុទ្ធសាស្ត្រជាតិ ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ ប្រព័ន្ធធានាសុវត្ថិភាព និងផែនការហិរញ្ញប្បទាន សុទ្ធតែគាំទ្រលទ្ធភាពរបស់កម្ពុជាក្នុងការកៀរគរហិរញ្ញវត្ថុពីប្រភពមូលនិធិជាច្រើន រួមទាំងពីម្ចាស់ជំនួយអន្តរជាតិ និងពីទីផ្សារកាបូនស្ម័គ្រចិត្ត។ ប៉ុន្តែនៅពេលដែលភាគច្រើននៃថវិកាទាំងនេះស្ថិតនៅក្នុងកញ្ចប់រួមគ្នាមួយ កត្តាដ៏សំខាន់មួយគឺសមត្ថភាពក្នុងការបង្ហាញឱ្យឃើញថា ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានភាពជឿជាក់និងគួរឱ្យជឿទុកចិត្តក្នុងកម្រិតខ្ពស់បាន។ ដើម្បីផ្តល់ការធានានេះបាន កម្ពុជាបច្ចុប្បន្នស្ថិតក្នុងចំណោមប្រទេសមួយចំនួនតូច ដែលកំពុងអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិ «សុខដុមនីយកម្មបដិបត្តិ» ដែលនឹងជួយឱ្យប្រទេសនេះទទួលបានទុនពេញលេញតាមការរំពឹងទុករបស់កម្មវិធីរេដបូក។

ឧបសគ្គដែលមានជាយូរមកហើយគឺថា គម្រោងរេដបូកនានាប្រើប្រាស់ទិន្នន័យ និងវិធីផ្សេងៗគ្នា ដើម្បីវាស់វែងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីព្រៃឈើ និងការរួមចំណែកនៃវិធានការបន្ធូរបន្ថយ។ ឧបសគ្គនេះបានបង្កឱ្យមានការលំបាកក្នុងការរាយការណ៍អំពីវឌ្ឍនភាពឱ្យបានត្រឹមត្រូវ។ វាអាចនាំឱ្យមានការរាប់កាបូនត្រួតលើគ្នា ឬខុសគ្នា ដែលមានគម្រោងមួយចំនួនមានកិច្ចខិតខំប្រឹងប្រែងតិចតួច ប៉ុន្តែបានទទួលថវិកាច្រើន ។ ភាពមិនស៊ីសង្វាក់គ្នានេះ បើបណ្តោយទុកឱ្យនៅកើតមានឡើងកាន់តែយូរ អាចធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ហិរញ្ញវត្ថុសាធារណៈនិងឯកជន ហើយសូម្បីតែការគាំទ្រចំពោះកិច្ចការពារព្រៃឈើក៏អាចនឹងមានផលប៉ះពាល់ផងដែរ។

ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ កម្ពុជាបច្ចុប្បន្នស្ថិតក្នុងចំណោមប្រទេសមួយចំនួនតូច ដែលកំពុងអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិស្តីពី «ប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូក»។ ប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូក ដំណើរការទៅបានតាមរយៈការកំណត់ច្បាប់និងនិតិវិធីរួមទូទៅ ដើម្បីគណនានិងតាមដានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងលើកកម្ពស់ការធានាសុវត្ថិភាពសង្គម និងបរិស្ថាន។ ប្រព័ន្ធនេះបន្សុីការវាស់វែងឧស្ម័នផ្ទះកញ្ចក់របស់គម្រោងនិងតំបន់នានានៅក្នុងប្រទេស ឱ្យស្របតាមបទដ្ឋានរបស់ជាតិ ហើយការកំណត់ទិន្នន័យគ្រាដើម និងកម្រិតយោង ត្រូវតែចាប់ផ្តើមចេញពីចំណុចរួមមួយដូចគ្នា។ ការខំប្រឹងប្រែងស្មើគ្នាទទួលបានរង្វាន់ស្មើគ្នា ហើយអត្ថប្រយោជន៍ត្រូវបានចែករំលែកដោយស្មើភាព។ ការលើកកម្ពស់តម្លាភាពនិងសុច្ចរិតភាពផ្នែកបរិស្ថានឱ្យកាន់តែមានភាពប្រសើរឡើងនឹងបញ្ជូនសញ្ញាវិជ្ជមានទៅកាន់ម្ចាស់ជំនួយនិងទីផ្សារអន្តរជាតិ ជាមួយនឹងឥណទានកាបូនមានគុណភាពខ្ពស់ អាចបើកចហរទ្វារកាន់តែទូលំទូលាយទៅកាន់ហិរញ្ញវត្ថុថ្មីៗ បន្ថែមពីលើថវិកាជាតិនិងវិភាគទានរបស់ដៃគូអភិវឌ្ឍ។

ប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូក មានភាពលំបាកក្នុងការរៀបចំនិងការអនុវត្ត ដែលទាមទារឱ្យមានកិច្ចសហការជិតស្និទ្ធ រវាងស្ថាប័ន អភិក្រម និងទិន្នន័យផ្សេងៗ ដែលគាំទ្រដល់ការបង្កើតនិងការជម្រុញដល់ការអនុវត្តបទប្បញ្ញត្តិទាំងនោះ។ ប្រទេសកម្ពុជាបានសម្រេចជ្រើសរើសយកការអនុវត្តប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូកតាមវិធីសាស្ត្រជាដំណាក់កាល។ ក្នុងអំឡុងពេលអន្តរកាលនៅឆ្នាំ២០២១ គម្រោងរេដបូកនានានឹងបន្តប្រតិបត្តិការដូចធម្មតា។ បន្ទាប់ពីឆ្នាំ២០២២ គម្រោងរេដបូកទាំងអស់ត្រូវតែអនុវត្តតាមបទប្បញ្ញត្តិថ្មីស្តីពីការតាមដានកត់ត្រាការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងត្រូវតែចុះបញ្ជីនៅក្នុងមូលដ្ឋានទិន្នន័យរេដបូកជាតិ ដើម្បីទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

បទប្បញ្ញត្តិដែលគេបានស្គាល់ថាជា "ប្រកាស" បានផ្តល់ការគាំទ្រផ្លូវច្បាប់ និងរចនាសម្ព័ន្ធដល់ការបង្កើតប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូនៅកម្ពុជា។ បទប្បញ្ញត្តិនេះ កំណត់នូវវិធីសាស្ត្រក្នុងការវាស់វែង សិទ្ធក្នុងការទទួលបានកាបូន និងការចុះបញ្ជីនៅក្នុងមូលដ្ឋានទិន្នន័យរេដបូកជាតិ។ បទប្បញ្ញត្តិនេះ នឹងណែនាំផងដែរនូវវឌ្ឍនភាពឆ្ពោះទៅកាន់ការសម្រេចបានការអនុវត្តប្រព័ន្ធសុខដុម្មនីយកម្មបដិបត្តិរេដបូកពេញលេញ នៅពេលដែលទិន្នន័យមានភាពរឹងមាំគ្រប់គ្រាន់ហើយមុខងារនានា ដូចជាការចុះបញ្ជីរគម្រោងរេដបូក និងការរាយការណ៍អំពីការធានាសុវត្ថិភាពត្រូវបានដាក់បញ្ចូលពេញលេញជាផ្នែកមួយនៃមុខងាររបស់ស្ថាប័ន។

### ប្រអប់ទី៧៖ ចំណាប់អារម្មណ៍របស់សាធារណៈ និងឯកជនលើប្រព័ន្ធសុខដុមនីយកម្មមានការកើនឡើង

ប្រទេសជាច្រើនដូចជាជប៉ុន សាធារណរដ្ឋកូរ៉េ និងស្វីស ក៏ដូចជាសហភាពអឺរ៉ុប បានគូសបញ្ជាក់ពីការបោះជំហានទៅមុខរបស់កម្ពុជាក្នុងការលើកកម្ពស់គណនេយ្យភាពចំពោះកាបូនពាក់ព័ន្ធនឹងព្រៃឈើ ហើយបានប្រកាសពីការចូលរួមសហការស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍។ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនហិរញ្ញវត្ថុកាបូន ក៏បានបង្ហាញពីចំណាប់អារម្មណ៍ខ្ពស់ក្នុងការចូលរួមគាំទ្រដល់ការអនុវត្តគោលការណ៍ណែនាំស្តីពីប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូក។

ក្រុមហ៊ុនឯកជនមួយចំនួន ក៏បានគូសបញ្ជាក់ចំណាប់អារម្មណ៍ខ្លាំង ក្នុងការទិញឥណទានកាបូនពីគម្រោងសុខដុមនីយកម្មបដិបត្តិរេដបូកទាំងនេះ ដោយសារតែការធានាបាននូវសុក្រឹត្យភាពកាបូនខ្ពស់។ ក្រុមហ៊ុនទាំងនេះកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ពីការដឹកនាំរបស់កម្ពុជានៅក្នុងការអនុវត្តប្រព័ន្ធនេះ។

### ប្រអប់ទី៨៖ ចលករថ្មីសម្រាប់សុច្ចរិតភាពកាបូន

គំនិតផ្តួចផ្តើមស្តីពីសុច្ចរិតភាពទីផ្សារកាបូនស្មគ្រចិត្ត គឺជាវេទិការថ្មីមួយ ដែលប្រមូលផ្តុំរដ្ឋាភិបាល អាជីវកម្ម និងតួអង្គផ្សេងទៀត ដើម្បីជម្រុញដល់ការលើកកម្ពស់ទីផ្សារកាបូនដែលមានទំនុកចិត្តខ្ពស់ តម្លាភាព និងផ្សារភ្ជាប់ជាមួយគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឱ្យនៅកម្រឹតសូន្យ។ តាមរយៈការបន្តពិគ្រោះយោបល់ ភាគីពាក់ព័ន្ធកំពុងតែលើកស្នើឡើងនូវស្តង់ដារនានាសម្រាប់ទីផ្សារកាបូនដែលមានគុណភាពខ្ពស់ ដែលអាចលំហូរហិរញ្ញវត្ថុពីវិស័យឯកជនច្រើនគាំទ្រដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ កម្ពុជាបានចូលរួមនៅក្នុងគំនិតផ្តួចផ្តើមនេះ ព្រមទាំងបានគូសបញ្ជាក់ពីវឌ្ឍភាពដែលខ្លួនសម្រេចបានស្តីពីការរៀបចំប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូក ដែលជាវិធីសាស្ត្រមួយគាំទ្រដល់ទិសដៅនៃគំនិតផ្តួចផ្តើមនេះ។

### ក្រាហ្វិកទី៨៖ តើអ្វីទៅជាប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូក?

លេខាធិការដ្ឋាននៃក្រុមការងាររេដបូក ក្រោមឱវាទរបស់ក្រសួងបរិស្ថាន បាននិងកំពុងរៀបចំក្របខ័ណ្ឌប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូកនេះឡើង។រូបភាពខាងក្រោមបង្ហាញពីគំនូសតាងតាមមូលបទនៃប្រព័ន្ធទាំងមូលសម្រាប់ការរៀបចំក្របខ័ណ្ឌនេះ។






# ៧. ឆ្ពោះទៅកាន់ការអនុវត្តជំហានបន្ទាប់



ផ្អែកតាមការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC) រេដបូកនឹងមានសារៈសំខាន់បំផុតសម្រាប់ផ្តល់ហិរញ្ញប្បទានគាំទ្រសកម្មភាពប្រកបដោយមហិច្ឆតាទាំងនេះ ដើម្បីពន្លឿនដល់ការសម្រេចបាននូវវឌ្ឍនភាព។ មូលដ្ឋានគ្រឹះមានរួចជាស្រេចហើយ ដើម្បីចាប់ផ្តើមការផ្លាស់ប្តូរដ៏ឆាប់រហ័សនេះ ហើយបច្ចុប្បន្ន ប្រទេសកម្ពុជាផ្តល់ក្តីសង្ឃឹមដ៏អស្ចារ្យសម្រាប់ការបង្ហាញអំពីសក្តានុពលដ៏ទូលំទូលាយរបស់រេដបូករួមបញ្ចូលទាំងប្រព័ន្ធសុខដុមនីយកម្មបដិបត្តិរេដបូក ដែលប្រព័ន្ធនេះរួមចំណែកដ៏សំខាន់ក្នុងការកែលម្អឱ្យកាន់តែប្រសើរឡើងនូវគុណភាពនិងសុចរិតភាពនៃដំណើរការចេញប័ណ្ណឥណទានកាបូន និងមានសក្តានុពលខ្ពស់ សម្រាប់ការចាប់យកប្រភពថ្មីៗនៃហិរញ្ញវត្ថុសាធារណៈនិងឯកជន។

យ៉ាងណាក៏ដោយ កម្ពុជាក៏ត្រូវបង្រួមគម្លាតមួយចំនួនដែរ ក្នុងនោះអាទិភាពបន្ទាន់មួយគឺការពន្លឿនការរៀបចំប្រព័ន្ធសមស្របមួយសម្រាប់បង្ហូរហិរញ្ញវត្ថុរេដបូក និងសម្រាប់ធានានិរន្តរភាពបន្ទុកចំណាយលើប្រតិបត្តិការ តាមរបៀបដែលអាចព្យាករណ៍បាន។ អាទិភាពបន្ទាប់គឺការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិឱ្យបានទូលំទូលាយ។ កិច្ចការទាំងនេះអាចនាំមកនូវការយល់ដឹងដ៏មានប្រយោជន៍សម្រាប់ការធ្វើផែនការសេដ្ឋកិច្ចនិងជម្រើសវិនិយោគ ព្រមទាំងអាចផ្តល់ទិន្នន័យស្តីពីសូចនាករជីវចម្រុះនិងសុខភាពព្រៃឈើផងដែរ។


© CAMBODIA RTS

ភាពជោគជ័យនៃការអនុវត្តរេដបូក នឹងពឹងផ្អែកភាគច្រើនលើការអនុវត្តគោលនយោបាយនិងបទប្បញ្ញត្តិនានា ដូចជាប្រកាស ដែលផ្តល់ភាពច្បាស់លាស់ផ្នែកច្បាប់ ដល់គម្រោងនិងអ្នកវិនិយោគ និងគោលការណ៍ណែនាំជាក់លាក់ដល់អ្នកអភិវឌ្ឍគម្រោង។ ការចូលរួមទូលំទូលាយប្រកបដោយអត្ថន័យពីសំណាក់ក្រសួងស្ថាប័នជាតិពាក់ព័ន្ធគឺជាប្រការចាំបាច់បំផុត។ រហូតមកដល់ពេលនេះ បណ្តាក្រសួងស្ថាប័នគ្រប់គ្រងព្រៃឈើនិងបរិស្ថាន បានដើរតួនាទីយ៉ាងសំខាន់ ប៉ុន្តែវិស័យនានា ដូចជាកសិកម្ម ថាមពល ហេដ្ឋារចនាសម្ព័ន្ធ និងរ៉ែ មិនទាន់បានចូលរួមគ្រប់គ្រាន់នៅឡើយ ទោះបីជាវិស័យទាំងនេះបានរួមចំណែកជំរុញដល់ការបាត់បង់ព្រៃឈើ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក៏ដោយ។ ការដាក់បញ្ចូលរេដបូកនៅក្នុងផែនការស្នូលរបស់ក្រសួងស្ថាប័នទាំងនេះ ព្រមទាំងការបែងចែកហិរញ្ញវត្ថុសមស្រប អាចលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើន រួមជាមួយការសម្របសម្រួលកាន់តែជិតស្និតរវាងវិស័យទាំងនោះ។

កង្វះសមត្ថភាពបច្ចេកទេសនិងប្រតិបត្តិការ នៅតែជាកង្វល់ជាប្រចាំ រួមទាំងសមត្ថភាពក្នុងការវាស់វែង និងតាមដានវឌ្ឍនភាពលើគម្របព្រៃឈើនិងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងការពិចារណាអំពីសមភាពយេនឌ័រ និងការអនុវត្តប្រព័ន្ធធានាសុវត្ថិភាពសង្គមនិងបរិស្ថាន។ ការខ្វះខាតជាទូទៅមានសភាពធំធេងនៅថ្នាក់ក្រោមជាតិ ដែលទាមទារឱ្យមានការផ្តោតការយកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាលនិងការផ្តល់ការណែនាំឱ្យបានគ្រប់ជ្រុងជ្រោយ។

យុទ្ធសាស្ត្ររេដបូកជាតិរបស់កម្ពុជាបានអំពាវនាវយ៉ាងត្រឹមត្រូវឱ្យមាន ការកែលម្អផែនការប្រើប្រាស់ដី។ ការបញ្ជាក់បន្ថែមអំពីនីតិវិធីសម្រាប់ការបែងចែកដី អាចលើកទឹកចិត្តសហគមន៍មូលដ្ឋានឱ្យទទួលយកការគ្រប់គ្រងធនធានធម្មជាតិនិងមធ្យោបាយចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពបន្ថែមទៀត។ រឿងនេះអាចធ្វើឱ្យប្រសើរឡើងនូវសិទ្ធិកាន់កាប់ដីធ្លី ជាពិសេស សម្រាប់សហគមន៍ជនជាតិដើមភាគតិច។ ការងារទាំងនេះអាស្រ័យទៅលើការសម្របសម្រួលច្បាស់លាស់រវាងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការផ្តល់ថវិកាគាំទ្រគ្រប់គ្រាន់ និងការចូលរួមជាប្រចាំនិងប្រកបដោយអត្ថន័យពីសំណាក់សហគមន៍នៅមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

ជារួម បទពិសោធន៍របស់កម្ពុជាបង្ហាញអំពីភាពស្មុគស្មាញនៃការបង្កើតកម្មវិធីរេដបូក។ ដំណើរការនេះបានចំណាយពេលវេលានិងការប្រឹងប្រែងច្រើន។ ប៉ុន្តែវាក៏បានបង្ហាញច្បាស់ពីតម្លៃនិងភាពអាចអនុវត្តបាននៃវិធីសាស្ត្រនេះផងដែរ។ តាំងពីដើមទីមក គោលដៅចម្បងគឺធានាថាព្រៃឈើបន្តផ្តល់ជាទំនិញនិងសេវាកម្មសម្រាប់ប្រជាជន ហើយក្នុងពេលជាមួយគ្នានេះដែរជួយពន្យឺតល្បឿននៃការប្រែប្រួលអាកាសធាតុក្នុងសកលលោក និងទ្រទ្រង់ជីវៈចម្រុះឱ្យមានចីរភាព។ តាមរយៈរេដបូក គោលដៅនោះកាន់តែជិតសម្រេចបាន។


© CAMBODIA RTS


© CAMBODIA RTS


© CAMBODIA RTS

## របាយការណ៍វឌ្ឍភាពស្តីពីវិធីសាស្ត្រអនុវត្តរេដបូកនៅកម្ពុជា

ឯកសារនេះអនុញ្ញាតឲ្យផលិតឡើងវិញទាំងស្រុងឬប្រើប្រាស់ផ្នែកណាមួយក្នុងគោលបំណងអប់រំ និងផ្សព្វផ្សាយ ដែលមិនទាញយកប្រាក់ដោយគ្រាន់តែបញ្ជាក់ឲ្យបានច្បាស់ពីស្ថាប័នដែលរៀបចំឯកសារនេះ។


**លេខាធិការដ្ឋានរេដបូកកម្ពុជា**
**Cambodia REDD+ Secretariat**

**រៀបចំដោយ:** លេខាធិការដ្ឋានរេដបូកកម្ពុជា
**ផលិត:** ខែឧសភា ២០២១
**អាស័យដ្ឋាន:** អាគារមរតកតេជោលេខ 503 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Tel:** (+855) 12 345 573
**Email:** redd.secretariat@cambodia-redd.org
**Website:** www.cambodia-redd.org
**Facebook:** Cambodia REDD+ National Programme


FOREST CARBON PARTNERSHIP FACILITY

UNDP